# ក្រមប្រតិបត្តិរបស់អ្នកផ្គត់ផ្គង់

នៅក្រុមហ៊ុន Fruit of the Loom និងបុត្រសម្ព័ន្ធក្រុមហ៊ុនរបស់យើង (“FOTL”) យើងប្ដេជ្ញាចិត្តធ្វើអាជីវកម្មយោងតាមបទដ្ឋានខ្ពស់បំផុតនៃក្រមសីលធម៌អាជីវកម្ម និងការគោរពសិទ្ធិមនុស្ស និងបរិស្ថាន។ យើងតម្រូវឲ្យមានការប្ដេជ្ញាចិត្តដូចគ្នា មកពីគ្រប់បរិក្ខារទាំងអស់ដែលផ្គត់ផ្គង់ដល់ផលិតផលរបស់យើង ដែលរួមមានជាអាទិ៍ អ្នកម៉ៅការ អ្នកទទួលអាជ្ញាប័ណ្ណ និងដៃគូពាណិជ្ជកម្មដែលត្រូវបានចាត់តាំងដទៃទៀត (ដែលត្រូវហៅជារួមថា “អ្នកផ្គត់ផ្គង់”)។ ក្រមសីលធម៌សម្រាប់អ្នកផ្គត់ផ្គង់នេះឆ្លុះបញ្ចាំងពីបទដ្ឋាន ដែលតាមរយៈនោះ យើងធានាថាអ្នកផ្គត់ផ្គង់បំពេញតាមការប្ដេជ្ញាចិត្ត ហើយទទួលបានការណែនាំតាមរយៈគោលការណ៍ពីអនុសញ្ញាជាមូលដ្ឋានរបស់អង្គការពលកម្មអន្តរជាតិ និងក្រមសីលធម៌នៃសមាគមការងារប្រកបដោយយុត្តិធម៌។

## ***ការផ្តោតទៅលើមនុស្ស***

ទំនាក់ទំនងការងារ៖ អ្នកផ្គត់ផ្គង់នឹងអនុវត្ត និងប្រកាន់ខ្ជាប់នូវច្បាប់ និងលក្ខខណ្ឌការងារដែលគោរពកម្មករនិយោជិត និងយ៉ាងហោចណាស់ការពារសិទ្ធិរបស់ពួកគេក្រោមច្បាប់ និងបទបញ្ញត្តិជាតិ និងអន្តរជាតិស្ដីពីការងារ និងសន្តិសុខសង្គម។

សុខភាពនិងសុវត្ថិភាព៖ អ្នកផ្គត់ផ្គង់នឹងផ្តល់កន្លែងធ្វើការដែលមានសុវត្ថិភាព និងនាំមកនូវសុខភាពល្អដើម្បីបង្ការការរងរបួស និងគ្រោះថ្នាក់ដល់សុខភាពដែលកើតចេញពីប្រតិបត្តិការរបស់អ្នកផ្គត់ផ្គង់។ លក្ខខណ្ឌក្នុងក្រុមហ៊ុនរបស់អ្នកផ្គត់ផ្គង់រួមទាំងលំនៅដ្ឋានដែលកាន់កាប់ ឬប្រើប្រាស់ដោយអ្នកផ្គត់ផ្គង់ត្រូវតែមានសុវត្ថិភាព មានអនាម័យ និងបំពេញឬលើសពីលក្ខខណ្ឌនៃច្បាប់ និងបទបញ្ញត្តិទាំងអស់ចូលដែលចូលជាធរមានទាក់ទិនទៅនឹងសុវត្ថិភាព និងសុខភាព។ កម្មករនិយោជិកត្រូវតែទទួលការបណ្តុះបណ្តាល និងបំពាក់បំប៉នដើម្បីអនុវត្តការងាររបស់ខ្លួនប្រកបដោយសុវត្ថិភាព។

ពលកម្មកុមារ៖ អ្នកផ្គត់ផ្គង់នឹងមិនផ្តល់ការងារឲ្យបុគ្គលដែលរំលោភលក្ខខណ្ឌនៃអាយុចូលរៀនតម្រូវដោយច្បាប់ក្នុងស្រុក ឬអាយុធ្វើការស្របតាមច្បាប់ចូលជាធរមានឡើយ។ គ្មានករណីណាមួយដែលអ្នកផ្គត់ផ្គង់ត្រូវផ្តល់ការងារដល់កម្មករនិយោជិតដែលមានអាយុក្រោម 15 ឆ្នាំឡើយ លើកលែងតែតារាសម្ដែង ឬតារាម៉ូដែលជាកុមារដែលត្រូវបានប្រើប្រាស់ក្នុងការផ្សព្វផ្សាយពាណិជ្ជកម្ម ឬប្រព័ន្ធផ្សព្វផ្សាយ ហើយនិងត្រូវតែអនុវត្តតាមបទបញ្ញត្តិស្តីពីពលកម្មកុមារដែលចូលជាធរមាន។

ការងារបង្ខំ៖ អ្នកផ្គត់ផ្គង់នឹងមិនប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំរួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែកម្លាំងពលកម្មក្នុងពន្ធនាគារ ការងារជាប់កិច្ចសន្យា ឬជាទាសករ ឬការងារសងបំណុល។ អ្នកផ្គត់ផ្គង់នឹងអនុវត្តវិធានការដើម្បីធានាថា សម្ភារៈបរិក្ខារមិនត្រូវបានប្រើប្រាស់ក្នុងការជួញដូរមនុស្សហើយនឹងត្រួតពិនិត្យខ្សែសង្វាក់ផ្គត់ផ្គង់របស់ពួកគេចំពោះការអនុវត្តទាំងនេះ។

ការបៀតបៀន ឬការរំលោភបំពាន៖ អ្នកផ្គត់ផ្គង់ត្រូវតែគោរពកម្មករនិយោជិតទាំងអស់ដោយសេចក្តីគោរព និងសេចក្តីថ្លៃថ្នូរ។ អ្នកផ្គត់ផ្គង់នឹងអនុវត្តនីតិវិធីដើម្បីធានាថា គ្មានកម្មករនិយោជិតណារងការបៀតបៀន ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត ឬផ្លូវវាចារណាមួយទេ។

ការមិនរើសអើង៖ អ្នកផ្គត់ផ្គង់មិនត្រូវមិនរើសអើងក្នុងការងាររួមទាំងការជួល ការផ្តល់សំណង ការដំឡើងឋានៈ វិន័យ ការបញ្ចប់កិច្ចសន្យាការងារ ឬការចូលនិវត្តន៍ដោយផ្អែកលើភេទ ពូជសាសន៍ សាសនា អាយុ ពិការភាព ទំនោរផ្លូវភេទ សញ្ជាតិ ការចូលជាសមាជិកសហជីព ទស្សនៈនយោបាយ ក្រុមក្នុងសង្គម ឬជនជាតិឡើយ។

ម៉ោងធ្វើការ៖ អ្នកផ្គត់ផ្គង់មិនត្រូវតម្រូវឱ្យកម្មករនិយោជិតធ្វើការលើសពីម៉ោងធ្វើការធម្មតា និងម៉ោងបន្ថែមដែលអនុញ្ញាតដោយច្បាប់ចូលជាធរមានឡើយ។ ក្នុងករណីថ្ងៃធ្វើការធម្មតាប្រចាំសប្តាហ៍មិនត្រូវលើសពី 48 ម៉ោង ហើយកម្មករនិយោជិតនឹងត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកយ៉ាងហោចណាស់ 24 ម៉ោងជាប់គ្នារាល់រយៈពេលប្រាំពីរថ្ងៃ។ ការងារបន្ថែមម៉ោងទាំងអស់នឹងត្រូវមានការព្រមព្រៀងគ្នា។ អ្នកផ្គត់ផ្គង់មិនត្រូវស្នើសុំបន្ថែមម៉ោងជាប្រចាំទេ ហើយនឹងទូទាត់សំណងសម្រាប់ការងារបន្ថែមម៉ោងក្នុងអត្រាខ្ពស់។ ក្រៅពីក្នុងករណីពិសេស ការបូកម៉ោងធ្វើការធម្មតា និងម៉ោងបន្ថែមក្នុងមួយសប្តាហ៍មិនត្រូវលើសពី 60 ម៉ោងឡើយ។

សំណង៖ រាល់កម្មករនិយោជិតទាំងអស់មានសិទ្ធិទទួលបានសំណងសម្រាប់ថ្ងៃធ្វើការងារធម្មតាប្រចាំសប្តាហ៍ ដែលគ្រប់គ្រាន់ល្មមបំពេញតម្រូវការជាមូលដ្ឋានរបស់កម្មករនិយោជិត និងផ្តល់ប្រាក់ចំណូលសល់ខ្លះបន្ទាប់ពីកាត់កងចំណាយរួច។ អ្នកផ្គត់ផ្គង់នឹងផ្តល់យ៉ាងហោចណាស់ប្រាក់ឈ្នួលអប្បបរមា ឬប្រាក់ឈ្នួលទូទៅសមរម្យ ដែលប្រាក់ឈ្នួលណាច្រើនជាងគេ អនុវត្តតាមលក្ខខណ្ឌផ្នែកច្បាប់ទាំងអស់អំពីប្រាក់ឈ្នួល និងផ្តល់នូវអត្ថប្រយោជន៍បន្ថែមណាមួយដែលតម្រូវដោយច្បាប់ ឬកិច្ចសន្យា។ ក្នុងករណីសំណងមិនបានបំពេញតាមតម្រូវការជាមូលដ្ឋានរបស់កម្មករនិយោជិត និងផ្តល់ប្រាក់ចំណូលសល់ខ្លះបន្ទាប់ពីកាត់កងចំណាយរួច អ្នកផ្គត់ផ្គង់នឹងចាត់វិធានការសមស្របដែលធ្វើយ៉ាងណាសម្រេចឲ្យបាននូវកម្រិតនៃសំណងដែលបំពេញលក្ខខណ្ឌទាំងនោះ។

សេរីភាពបង្កើតសមាគមនិងការចរចាជាសមូហភាព៖ អ្នកផ្គត់ផ្គង់ត្រូវតែទទួលស្គាល់ និងគោរពសិទ្ធិរបស់កម្មករនិយោជិតចំពោះសេរីភាពបង្កើតសមាគមនិងការចរចាជាសមូហភាព។

## ***មនសិការចំពោះភពផែនដី***

អ្នកផ្គត់ផ្គង់នឹងអនុវត្តវិធានការទទួលខុសត្រូវដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃប្រតិបត្តិការរបស់ពួកគេទៅលើបរិស្ថាន។ នៅកម្រិតអប្បបរមា នេះតម្រូវឱ្យអ្នកផ្គត់ផ្គង់អនុវត្តតាមច្បាប់ក្នុងស្រុក និងច្បាប់អន្តរជាតិទាំងអស់ចូលជាធរមាន ដែលការពារបរិស្ថានរួមទាំងការទុកដាក់ និងការបោះចោលសារធាតុគ្រោះថ្នាក់ឲ្យបានត្រឹមត្រូវ និងខិតខំធ្វើអាជីវកម្មក្នុងលក្ខណៈមួយដែលកាត់បន្ថយការប្រើប្រាស់ថាមពលនិងកាកសំណល់ បង្កើនការប្រើប្រាស់ធនធានធម្មជាតិឲ្យមានប្រសិទ្ធភាព និងពង្រីកការកែច្នៃ។

## ***ភាពពិតប្រាកដនៃផលិតផល***

<u>អនុលោមតាមច្បាប់</u>៖ ក្រៅពីបំពេញលក្ខខណ្ឌនៃក្រមប្រតិបត្តិនេះ អ្នកផ្គត់ផ្គង់នឹងគោរពតាមច្បាប់ បទបញ្ញត្តិ និងសន្ធិសញ្ញាទាំងអស់ផ្សេងទៀតដែលអាចអនុវត្តចំពោះប្រតិបត្តិការរបស់ខ្លួន។

<u>ក្រមសីលធម៌អាជីវកម្ម</u>៖ អំពើពុករលួយ ការជំរិតទារប្រាក់ ការកិបកេង ឬការបន្លំផលិតផលឬធនធាននៃវត្ថុធាតុដោយអ្នកផ្គត់ផ្គង់ត្រូវបានហាមឃាត់ជាដាច់ខាត នៅក្នុងរូបភាពណាក៏ដោយ។ ការហាមប្រាមនេះរួមមានជាអាទិ៍ដូចជា ការផ្តល់ជូនឬការទទួលយកសំណូកជាថ្នូរទៅនឹងផលប្រយោជន៍មិនសមរម្យ ឬមិនសមទទួលបាន ឬការខកខានក្នុងការបង្ហាញប្រភពនៃវត្ថុធាតុដើមពេលមានការស្នើសុំ។ ការរំលោភបំពានលើបម្រាមនេះអាចឈានទៅដល់ការបញ្ចប់ភ្លាមនូវកិច្ចសន្យាការងាររបស់អ្នកផ្គត់ផ្គង់ដោយ FOTL និងធ្វើឲ្យអ្នកផ្គត់ផ្គង់រងការប្តឹងផ្តល់តាមផ្លូវច្បាប់។

<u>អ្នកម៉ៅការបន្ត</u>៖អ្នកផ្គត់ផ្គង់មិនត្រូវប្រើប្រាស់អ្នកម៉ៅការបន្តក្នុងការផលិតគ្រឿងបន្លាស់ ឬផលិតផលរបស់ FOTL ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពី FOTL ឡើយ លុះត្រាតែបន្ទាប់ពីអ្នកម៉ៅការបន្តបានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរដើម្បីអនុវត្តតាមក្រមប្រតិបត្តិន។

<u>ការអនុវត្តតាមច្បាប់គយ</u>៖ អ្នកផ្គត់ផ្គង់នឹងអនុវត្តតាមច្បាប់គយទាំងអស់ដែលចូលជាធរមាន និងបង្កើតនិងរក្សាកម្មវិធីផ្សេងៗដើម្បីការពារប្រឆាំងនឹងការដឹកជញ្ជូនផលិតផលដោយខុសច្បាប។

<u>សន្តិសុខ</u>៖ អ្នកផ្គត់ផ្គង់នឹងរក្សានិតិវិធីការពារសន្តិសុខដើម្បីការពារប្រឆាំងនឹងការដឹកជញ្ជូនទំនិញដែលមិនប្រកាសពន្ធគយ (ឧ. គ្រឿងញៀន និងទំនិញគេចពន្ធផ្សេងទៀត) ជាមួយនឹងផលិតផលរបស់ FOTL រួមទាំងប៉ុន្តែមិនបានកំណត់ត្រឹមតែការអនុលោមតាមលក្ខខណ្ឌនៃកម្មវិធីស្តីពីភាពជាដៃគូរវាងពាណិជ្ជកម្ម និងគយប្រឆាំងនឹងភេរវកម្ម (C-TPAT) សម្រាប់ការដឹកជញ្ជូនទៅកាន់សហរដ្ឋអាមេរិក។

## ***ការអនុវត្ត និងការពង្រឹងការអនុវត្ត***

<u>តម្រូវការនៃការបិទប្រកាស</u>៖ អ្នកផ្គត់ផ្គង់នឹងត្រូវបិទប្រកាសក្រមសីលធម៌នេះនៅក្នុងទីតាំងដែលងាយមើលឃើញ ដែលអាចចូលមើលបានដោយបុគ្គលិកនិងភ្ញៀវគ្រប់រូប ជាភាសាដែលបុគ្គលិកគ្រប់រូប រួមទាំងកម្មករជាជនចំណាកស្រុកមកពីបរទេស យល់បាន។ អ្នកផ្គត់ផ្គង់ត្រូវធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលកម្មករនិយោជិតទាំងអស់ជារៀងរាល់ឆ្នាំពាក់ព័ន្ធនឹងចំណុចផ្សេងៗនៃក្រមប្រតិបត្តិនេះ។

<u>ការរក្សាទុកកំណត់ត្រា</u>៖ អ្នកផ្គត់ផ្គង់នឹងរក្សាទុកកំណត់ត្រាពេញលេញ និងត្រឹមត្រូវពាក់ព័ន្ធនឹងចំណុចនីមួយនៃក្រមប្រតិបត្តិនេះ ដើម្បីអនុញ្ញាតឱ្យមានការផ្ទៀងផ្ទាត់ការអនុលោមតាមច្បាប។

<u>គោលការណ៍ណែនាំអ្នកផ្គត់ផ្គង់ សៀវភៅណែនាំស្តីពីការអនុលោមភាពសង្គមសម្រាប់អ្នកមានអាជ្ញាប័ណ្ណ</u>៖ ក្នុងករណីអាចអនុវត្តទៅបាន អ្នកផ្គត់ផ្គង់នឹងគោរពតាមតម្រូវការដូចដែលបានរៀបរាប់លម្អិតនៅក្នុងគោលការណ៍ណែនាំអ្នកផ្គត់ផ្គង់ និង/ឬ សៀវភៅណែនាំស្តីពីការអនុលោមភាពសង្គមសម្រាប់អ្នកមានអាជ្ញាប័ណ្ណ ដែលអាចរកបាននៅលើគេហទំព័រក្រុមហ៊ុនរបស់ FOTL៖ www.fotlinc.com។

<u>ការវាយតម្លៃ និងសកម្មភាពកែតម្រូវ</u>៖ FOTL ប្រើប្រាស់សវនកម្មផ្ទៃក្នុងក៏ដូចជាសវនករឯករាជ្យដើម្បីធ្វើការវាយតម្លៃនៅនឹងកន្លែង និង/ឬវាយតម្លៃតាមអនឡាញដើម្បីធានាបាននូវការអនុលោមតាមក្រមប្រតិបត្តិនេះ។ អ្នកផ្គត់ផ្គង់នឹងសហការយ៉ាងពេញទំហឹងលើការងារវាយតម្លៃទាំងអស់នេះហើយនឹងធ្វើកំណត់ត្រាលម្អិតអំពីការអនុលោមតាមច្បាប់សម្រាប់ការធ្វើការពិនិត្យឡើងវិញ។ អ្នកផ្គត់ផ្គង់នឹងធ្វើការជាមួយ FOTL ដើម្បីរៀបចំផែនការសកម្មភាពកែតម្រូវដើម្បីដោះស្រាយបញ្ហាអំពីការមិនអនុលោមតាមច្បាប់ដោយមានហេតុផលសមស្រប។

<u>ការរាយការណ៍អំពីការរំលោភបំពាន</u>៖ ដើម្បីរាយការណ៍អំពីការរំលោភបំពានទៅលើក្រមសីលធម៌នេះ ដែលគេសង្ស័យថាមាន សូមទាក់ទងមកកាន់ផ្នែកទំនួលខុសត្រូវក្នុងសង្គមរបស់សហគ្រាស FOTL តាមរយៈទូរសព្ទលេខ +1-270-935-2588 ឬតាមការអ៊ីមែលមកកាន់ code@fotlinc.com ឬដោយការស្កេនកូដនៅខាងស្តាំដោយប្រើឧបករណ៍ចល័ត។ សូមផ្តល់ព័ត៌មានឱ្យលម្អិតអំពីភាគីដែលពាក់ព័ន្ធ និងការបំពានដែលបានចោទប្រកាន់ វិធានការដែលបានចាត់ឡើងដើម្បីដោះស្រាយបញ្ហានោះដោយផ្ទាល់ និងព័ត៌មានទំនាក់ទំនងសម្រាប់យើងធ្វើការប្រាស្រ័យទាក់ទងដោយសម្ងាត់អំពីក្តីកង្វល់នោះ។ យើងហាមឃាត់ជាដាច់ខាតរាល់ការសងសឹកណាមួយទៅលើបុគ្គលដែលរាយការណ៍អំពីករណីល្មើសក្រមប្រតិបត្តិនេះ ឬជួយឬចូលរួមក្នុងលក្ខណៈណាមួយក្នុងការស៊ើបអង្កេតលើករណីល្មើសក្រមប្រតិបត្តិនេះ។ ករណីសងសឹកណាមួយគួរតែត្រូវបានរាយការណ៍ទៅ FOTL ដូចដែលបានរៀបរាប់ខាងលើ។

កែសម្រួលនៅក្នុងខែកុម្ភៈ ឆ្នាំ 2022